# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 154

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : កម្មវិធីវិមជ្ឈការសេវាសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុជំហ៊ានទី២ អនុកម្មវិធីទី១៖ គម្រោងសាលាជាតិរដ្ឋបាលមូលដ្ឋាន

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 04/12/20 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 30/06/26 |
| ៣. ចំណាយគម្រោងសរុប | $11,050,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងមហាផ្ទៃ |
| RESPONSIBLE UNIT | National School for Local Administration |
| អង្គភាពទទួលខុសត្រូវ | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| ៥. ស្ថានភាពគម្រោង | គម្រោងកំពុងដំណើរការ |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងស័ក្តិសិទ្ធភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនឹងចូលរួមចំណែកក្នុងការពង្រឹងស្ថាប័នបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពមន្រ្តីរាជការនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែល្អប្រសើរឡើង និងឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៏វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិបាលកិច្ច និងរដ្ឋបាល

Governance and Administration
ចូលរួមក្នុងការអភិវឌ្ឍធនធានមនុស្សដែលបានកំណត់ក្នុង ផ.យ.អ.ជ ២០១៩-២០២៣
Governance and Administration
ចូលរួមក្នុងការអភិវឌ្ឍធនធានមនុស្សដែលបានកំណត់ក្នុង ផ.យ.អ.ជ ២០១៩-២០២៣
Governance and Administration
ចូលរួមក្នុងការអភិវឌ្ឍធនធានមនុស្សដែលបានកំណត់ក្នុង ផ.យ.អ.ជ ២០១៩-២០២៣

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

សាង់សង់សាលាជាតិរដ្ឋបាលមូលដ្ឋានដើម្បីផ្ដល់ការបណ្ដុះបណ្ដាលដល់មន្ត្រីរាជការរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណភាពដែលមានលក្ខណៈប្រព័ន្ធ និងធានាបាននូវនិរន្តរភាព។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

សមិទ្ធផលទី១៖ ការសាងសង់អគារសាលាជាតិរដ្ឋបាលមូលដ្ឋាន អន្តេវាសិកដ្ឋាននិងបំពាក់ឧបករ សម្ភារៈ
សមិទ្ធផលទី២៖ ការរៀបចំកម្មវិធីសិក្សាដើម្បីពង្រឹងគុណភាពបង្រៀន និងការបណ្ដុះបណ្ដាលដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និង
សមិទ្ធផលទី៣៖ ពង្រឹងស្ថាប័នសាលាជាតិរដ្ឋបាលមូលដ្ឋាន និងពង្រឹងសមត្ថភាពមន្ត្រី និងគ្រូបង្គោល។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

តាមរយៈគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ រដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវកាន់តែច្រើនក្នុងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋានតាមរយៈការផ្ទេរមុខងារ និងធនធានពីថ្នាក់ជាតិទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានសមត្ថភាពគ្រប់គ្រាន់ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះប្រកបដោយប្រសិទ្ធភាព និងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ គោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០)។ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការទាំងនេះ រាជរដ្ឋាភិបាលបានបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋានតាមរយៈអនុក្រឹត្យលេខ១៩២ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

មន្ត្រីរាជការស៊ីវិលនៅទីស្ដីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការបណ្ដុះបណ្ដាលប្រកបដោយគុណភាព ទន្ទឹមនឹងប្រជាពលរដ្ឋទទួលបានសេវាសាធារណៈកាន់តែប្រសើរ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | ត្រូវបានបញ្ចប់ |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះបានបញ្ចប់ការសិក្សាហេតុប៉ះពាល់ផ្នែកបរិស្ថាននៅកន្លែងទីតាំងសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន ហើយទទួលបានការឯកភាពនិងការអនុម័តពីក្រសួងបរិស្ថាន ហើយទីតាំងសាងសង់សាលាមិនពាក់ព័ន្ធនឹងបំលាស់ទីលំនៅរបស់ប្រជាពលរដ្ឋទេព្រោះទីតាំងដីនោះជាកម្មសិទ្ធរបស់ក្រសួងមហាផ្ទៃ។ ដោយឡែកគម្រោងនេះតែមានផលប៉ះពាល់ជាវិជ្ជមានផ្នែកសង្គម ចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សនៃរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយសមត្ថភាព ក្នុងការបំរើសេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង សំដៅចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ការសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងអន្តេវាសិកដ្ឋានត្រូវបានគិតគូរយ៉ាងល្អិតល្អន់អំពីផ្នែកយេឌ័រនិងមានផែនការសកម្មភាពពាក់ព័ន្ធនឹងយេឌ័រច្បាស់លាស់រួមមានការសាង ់សង់បន្ទប់ស្នាក់នៅក្នុងអន្តេវាសិកដ្ឋានត្រូវបានបែងចែកដាច់ពីគ្នារវាងស្ត្រី និងបុរស បង្គន់អនាម័យដាច់ពីគ្នារវាងស្ត្រីនិងបុរស និងទីលាន សម្រាប់ក្មេងលេង (កូនរបស់សិក្ខាកាម)។ល។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**សាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងឱ្យទទួលបានជោគជ័យតាមផែនការគម្រោង និងធានាបាននូវនិរន្តរភាពក្រោយបញ្ចប់គម្រោង។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

គម្រោងនេះបានចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០២១ ហើយបានរៀបចំគណៈកម្មការដឹកនាំគម្រោង គណៈកម្មការលទ្ធកម្ម និងអង្គភាពគ្រប់គ្រងគម្រោង។ រហូតដល់ពេលនេះគម្រោងជ្រើសរើសបានទីប្រឹក្សាគ្រប់គ្រងគម្រោងចំនួន៤រូប និងទីប្រឹក្សាផ្នែកអភិវឌ្ឍសមត្ថភាពបានចំនួន២រូប នៅក្នុងខែកក្កដា ឆ្នាំ២០២១ និងបានបញ្ចប់កិច្ចលទ្ធកម្មឧបករណ៍និងគ្រឿងសង្ហារឹម ក៏ដូចជ្រើសរើសបានក្រុមហ៊ុនគូរប្លង់សាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងអន្តេវាសិកដ្ឋាន កំពុងសិក្សានិងគូរប្លង់លម្អិតផ្នែកវិស្វកម្មព្រមទាំងបាននិងកំពុង រៀបចំកិច្ចលទ្ធកម្មរថយន្ត និងប្រកាសជ្រើសរើសក្រុមហ៊ុនប្រឹក្សាយោបល់ផ្នែករៀបចំកម្មវិធីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព គ្រូបង្គោល។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះទទួលបានការគាំទ្រពីកម្ចីរបស់ធនាគារអភិវឌ្ឍអាស៊ី (ADB Loan No. 3970-CAM) និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល។ សូមមើលកិច្ចព្រមព្រៀងកម្ចី។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 256.0 | 0.0 | 256.0 | 256.0 | 0.0 | 0.0 | 256.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 28.0 | 0.0 | 28.0 | 28.0 | 0.0 | 0.0 | 28.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 42.0 | 0.0 | 42.0 | 42.0 | 0.0 | 0.0 | 42.0 | 0.0 |
| ផ្សេងៗ | 186.0 | 0.0 | 186.0 | 186.0 | 0.0 | 0.0 | 186.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 2,446.0 | 221.5 | 3,554.0 | 282.0 | 0.0 | 0.0 | 282.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 1,816.0 | 0.0 | 2,722.0 | 42.0 | 0.0 | 0.0 | 42.0 | 0.0 |
| សេវាទីប្រឹក្សា | 630.0 | 0.0 | 742.0 | 240.0 | 0.0 | 0.0 | 240.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 90.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 221.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 2,702.0 | 221.5 | 3,810.0 | 538.0 | 0.0 | 0.0 | 538.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 215.0 | 0.0 | 215.0 | 215.0 | 0.0 | 0.0 | 215.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 215.0 | 0.0 | 215.0 | 215.0 | 0.0 | 0.0 | 215.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 2,487.0 | 221.5 | 3,595.0 | 323.0 | 0.0 | 0.0 | 323.0 | |
| | | | | | | | | |
| Asian Development Bank | 2,487.0 | 221.5 | 3,595.0 | 323.0 | 0.0 | 0.0 | 323.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 2,702.0 | 221.5 | 3,810.0 | 538.0 | 0.0 | 0.0 | 538.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: